មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា
Cambodian Center for Human Rights

# សេចក្តីប្រកាសព័ត៌មាន

## មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជាចាប់ផ្តើមធ្វើយុទ្ធនាការប្រចាំឆ្នាំដើម្បីប្រារព្ធ ទិវាសិទ្ធិមនុស្សអន្តរជាតិសំខាន់ៗ

រាជធានីភ្នំពេញ ថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥

នៅថ្ងៃទី២៥ ខែវិច្ឆិកា ឆ្នាំ២០២៥ មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») នឹងចាប់ផ្តើមធ្វើយុទ្ធនាការ ១៦ ថ្ងៃ ប្រចាំឆ្នាំរបស់ខ្លួន ដើម្បីបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ។

កាលបរិច្ឆេទសំខាន់នេះ ជាការប្រារព្ធទិវាអន្តរជាតិដើម្បីលុបបំបាត់អំពើហិង្សាលើស្ត្រី។ អំពើហិង្សាលើស្ត្រីជាការរំលោភបំពានសិទ្ធិមនុស្សដែលកើតមានដ៏ច្រើន និងបង្កឱ្យមានផលប៉ះពាល់យ៉ាងធ្ងន់ធ្ងរលើពិភពលោក និងនៅក្នុងប្រទេសកម្ពុជានាពេលបច្ចុប្បន្ន។ តាមការប៉ាន់ប្រមាណ ស្ត្រីកម្ពុជាច្រើនជាងម្នាក់ក្នុងចំណោមប្រាំនាក់ធ្លាប់រងការរំលោភបំពានពីសំណាក់ដៃគូរបស់ខ្លួន។ យុទ្ធនាការ ១៦ ថ្ងៃ របស់ ម.ស.ម.ក នឹងលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិរបស់ស្ត្រី និងបង្ហាញពីផលប៉ះពាល់ដែលបង្កឡើងពីអំពើហិង្សាទាក់ទងនឹងយេនឌ័រ ព្រមទាំងអំពាវនាវដល់រាជរដ្ឋាភិបាលកម្ពុជាឱ្យមានវិធានការសមស្រប និងជាក់លាក់ជាបន្ទាន់ ដើម្បីបញ្ឈប់អំពើហិង្សាទាក់ទងនឹងយេនឌ័រ និងលើកកម្ពស់សមភាពយេនឌ័រនៅក្នុងប្រទេស។

យុទ្ធនាការនេះនឹងប្រព្រឹត្តទៅរហូតដល់ទិវាសិទ្ធិមនុស្សអន្តរជាតិថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ ដែលជាទិវាសំខាន់ក្នុងការប្រារព្ធខួបនៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្សដែលជាក្របខ័ណ្ឌសិទ្ធិមនុស្សអន្តរជាតិ និងបានបញ្ចូលនូវសិទ្ធិមនុស្សជាមូលដ្ឋានសម្រាប់មនុស្សគ្រប់រូបជាលើកដំបូង។

ក្នុងអំឡុងពេលនេះ ម.ស.ម.ក នឹងប្រារព្ធទិវាសំខាន់ផ្សេងៗទៀតស្របតាមប្រតិទិនសិទ្ធិមនុស្ស ក្នុងនោះរួមមាន ទិវាអន្តរជាតិនៃអ្នកការពារសិទ្ធិមនុស្សជាស្ត្រីនៅថ្ងៃទី២៩ ខែវិច្ឆិកា ឆ្នាំ២០២៥ និងទិវាអន្តរជាតិនៃអ្នកការពារសិទ្ធិមនុស្សនៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៥ ដែលជាកាលបរិច្ឆេទសំខាន់ក្នុងការរម្លឹកពីការប្តេជ្ញាចិត្ត និងឆន្ទៈមោះមុតរបស់អ្នកការពារសិទ្ធិមនុស្សក្នុងការតស៊ូមតិ ការអប់រំ និងការលើកកម្ពស់ការយល់ដឹងអំពីសិទ្ធិមនុស្សក្នុងសហគមន៍របស់យើង។

ជារួម យុទ្ធនាការនេះបង្កើតនូវឱកាសសម្រាប់ដៃគូពាក់ព័ន្ធ ជាពិសេស តួអង្គដែលមានកាតព្វកិច្ចក្នុងការការពារ និងលើកកម្ពស់សិទ្ធិមនុស្ស ដូចជា រាជរដ្ឋាភិបាល ដើម្បីបញ្ជាក់ឡើងវិញនូវកាតព្វកិច្ចរបស់ខ្លួនចំពោះការការពារ និងការលើកកម្ពស់សិទ្ធិមនុស្សព្រមទាំងទទួលស្គាល់ការចូលរួមចំណែករបស់អង្គការសង្គមស៊ីវិលផងដែរ។

តាមរយៈយុទ្ធនាការនេះចាប់ពីថ្ងៃទី២៥ ខែវិច្ឆិកា ដល់ថ្ងៃទី១០ ខែធ្នូ ២០២៥ ម.ស.ម.ក នឹងអនុវត្តសកម្មភាពមួយចំនួនជាបន្តបន្ទាប់ដូចខាងក្រោម៖

- នៅថ្ងៃទី២៥ ខែវិច្ឆិកា ដល់ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥ ម.ស.ម.ក នឹងអនុញ្ញាតឱ្យសាធារណជនអាចមកយកឯកសារបោះពុម្ពរបស់ ម.ស.ម.ក នៅការិយាល័យ។
- នៅថ្ងៃទី២៦ ខែវិច្ឆិកា ឆ្នាំ២០២៥ ម.ស.ម.ក នឹងធ្វើការផ្សព្វផ្សាយតាមរយៈអនឡាញនូវប្រធានបទមួយដែលមានចំណងជើងថា «ខ្ញុំចង់ដឹង» និងផ្តល់ឱកាសដល់សាធារណជនលើកជាសំណួរពាក់ព័ន្ធនឹងសិទ្ធិ

មនុស្សក្នុងប្រទេសកម្ពុជា ហើយសំណួរមួយចំនួននឹងត្រូវបកស្រាយដោយវាគ្មិនជំនាញ។

- នៅថ្ងៃទី២៨ ខែវិច្ឆិកា ដល់ថ្ងៃទី៥ ខែធ្នូ ឆ្នាំ២០២៥ ម.ស.ម.ក នឹងបើកឱ្យមានការចុះឈ្មោះជាសាធារណៈដើម្បីចូលរួមកម្មវិធីនេះដោយផ្ទាល់នៅថ្ងៃទី០៩ ខែធ្នូ។
- នៅថ្ងៃទី០៣ ខែធ្នូ ឆ្នាំ២០២៥ ម.ស.ម.ក នឹងចេញផ្សាយបណ្ណព័ត៌មានស្តីពីអ្នកស្រលាញ់ភេទដូចគ្នា និងសកម្មជនជាស្ត្រី ដែលបង្ហាញពីបញ្ហាប្រឈមរបស់ពួកគាត់ និងសារៈសំខាន់ក្នុងការចូលរួមលើកកម្ពស់សិទ្ធិមនុស្ស។
- នៅព្រឹកថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៥ ម.ស.ម.ក នឹងរៀបចំទិវាអន្តរជាតិនៃអ្នកការពារសិទ្ធិមនុស្ស ដោយមានការផ្សព្វផ្សាយវីដេអូដែលមានចំណងជើងថា «កុំបំភ្លេចពួកយើង៖ រួមគ្នាបន្តដំណើរទៅមុខ»។ វីដេអូនេះបង្ហាញពីអ្នកការពារសិទ្ធិមនុស្សជាស្ត្រី និងសកម្មភាពរបស់គាត់ក្នុងការលើកកម្ពស់សិទ្ធិមនុស្សក្នុងប្រទេសកម្ពុជា។
- នៅថ្ងៃទី០៩ ខែធ្នូ ឆ្នាំ២០២៥ ម.ស.ម.ក នឹងរៀបចំយុទ្ធនាការ ១៦ ថ្ងៃនេះ និងទិវាសិទ្ធិមនុស្សអន្តរជាតិនៅការិយាល័យរបស់ ម.ស.ម.ក។ កម្មវិធីនេះនឹងមានសម្តែងសិល្បៈដែលបង្ហាញពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេស ព្រមទាំងមានការជជែកពិភាក្សាអំពីប្រធានបទ«*សន្តិភាពមិនមានពេញលេញនោះទេ បើគ្មានការលើកកម្ពស់សិទ្ធិមនុស្ស*»។ កម្មវិធីនេះនឹងផ្តល់ឱកាសផងដែរដល់សាធារណជន សង្គមស៊ីវិល និងដៃគូពាក់ព័ន្ធអាចចូលរួមបាន។
- នៅថ្ងៃទី១០ ខែធ្នូ ឆ្នាំ២០២៥ ម.ស.ម.ក នឹងប្រារព្ធទិវាសិទ្ធិមនុស្សអន្តរជាតិ និងបិទបញ្ចប់យុទ្ធនាការនេះដោយមានចេញផ្សាយកាលប្បវត្តិស្តីពីសិទ្ធិមនុស្សឆ្នាំ២០២៥ ដែលបង្ហាញអំពីបញ្ហាសិទ្ធិមនុស្សក្នុងឆ្នាំ២០២៥ នេះ។

សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក **លឹម បូរិន** អ្នកសម្របសម្រួលគម្រោងនិន្នាការភេទ អត្តសញ្ញាណយេនឌ័រ ការបង្ហាញយេនឌ័រ និងលក្ខណៈភេទ របស់ ម.ស.ម.ក តាមរយៈទូរស័ព្ទ: + ៨៥៥ (០) ១២ ៩០៤ ២៦៦ ឬ អ៊ីម៉ែល: borin.lim@cchrcambodia.org៕

**-ចប់-**

**<u>បណ្ណាធិការ៖</u>**

មជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា («ម.ស.ម.ក») ជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្សសម្ព័ន្ធដែលធ្វើការដើម្បីលើកកម្ពស់និងការពារសិទ្ធិមនុស្ស ជាពិសេសសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ លទ្ធិប្រជាធិបតេយ្យ និងនីតិរដ្ឋនៅព្រះរាជាណាចក្រកម្ពុជា។

ម.ស.ម.ក ជាសមាជិកនៃដៃគូសន្ទនាអន្តរជាតិដើម្បីសេរីភាពបញ្ចេញមតិ (IFEX) បណ្តាញសកលដើម្បីសេរីភាពខាងការបញ្ចេញមតិ និងសម្ព័ន្ធពិភពលោកដើម្បីការចូលរួមពលរដ្ឋ (CIVICUS) ។ ម.ស.ម.ក ក៏ជាសមាជិកនៃអង្គការពិភពលោកប្រឆាំងនឹងទារុណកម្ម (OMCT) ជាសមាជិក OECD-Watch ជាសមាជិកនៃបណ្តាញប្រឆាំងទារុណកម្ម អែស អូ អែស និងសម្ព័ន្ធសារព័ត៌មានអាស៊ីអាគ្នេយ៍ (SEAPA) ផងដែរ។

គេហទំព័រអំពីសិទ្ធិមនុស្សកម្ពុជា www.sithi.org ជាជ័យលាភីដែលបានទទួលពានរង្វាន់មូលនិធិនៃការបង្កើតសារព័ត៌មានថ្មីប្រចាំឆ្នាំ២០១១ស្ថិតក្នុងប្រភេទ «សិទ្ធិ និងសេរីភាព» និងជាជ័យលាភីទទួលពានរង្វាន់ក្នុងឆ្នាំ២០១៣ ផ្នែកទំនាក់ទំនងដើម្បីផ្លាស់ប្តូរសង្គមមកពីមជ្ឈមណ្ឌលសម្រាប់ទំនាក់ទំនង និងការផ្លាស់ប្តូរសង្គមនៅសាកលវិទ្យាល័យឃ្វីនស្លែន ក្នុងទីក្រុងប្រ៊ីសបេន ប្រទេសអូស្ត្រាលី៕